# បទដ្ឋានីយ (ខ្នាតគំរូ) កសិកម្មសរីរាង្គ

## [Organic Agriculture Standards]

២០០៣

ពង្រាង

*រៀបចំ ដោយ អង្គការស្រែខ្មែរ*

*យកលំនាំតាម ACT Organic Agriculture standards, Thailand, May 2001, និង FOOD Link, Vietnam Association for basic Organic Agricultural standard, production and processing, July 1999.*

---

## [illegible] ការកែច្នៃ ការខ្ចប់ និង[illegible]

កសិកម្មសរីរាង្គ គឺជាដំណើរនៃការដាំដុះតាមបែបធម្មជាតិ ឬតាមបែបកសិកម្មអេកូឡូស៊ី ដែលមានគោលការណ៍ជាមូលដ្ឋានគ្រឹះ ដូចតទៅនេះ :

- **ថែរក្សាប្រព័ន្ធអេកូឡូស៊ីក្នុងការដាំដុះ**
  - ➢ មិនប្រើសារធាតុគីមីសំយោគ និង GMOs
  - ➢ ការពារការហូរច្រោះ ឬការបាត់បង់ជីជាតិដី ស្រទាប់ខាងលើ

- **ធ្វើអោយប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីក្នុងការដាំដុះ**
  - ➢ កែលំអសារធាតុចិញ្ចឹមក្នុងដី តាមរយៈការប្រើប្រាស់ជីកំប៉ុស្ត៍ និងសារធាតុសរីរាង្គផ្សេងៗទៀត
  - ➢ ថែរក្សាជីវសាស្ត្រចំរុះរបស់ចំការ

- **ធ្វើការដោយសុខដុម ជាមួយដំណើរវិវត្តន៍របស់ប្រព័ន្ធអេកូឡូស៊ីក្នុងចំការ**
  - ➢ ថែរក្សាឈើនិងប្រព័ន្ធអេកូឡូស៊ី ដែលនាំអោយមានការកើនឡើងនូវសត្វមានប្រយោជន៍
  - ➢ បង្កើនការចាប់យកសារធាតុអាហ្សូតដោយធម្មជាតិ
  - ➢ ការដាំដំណាំចំរុះ និងដំណាំបង្វិល

- **ការពារកុំអោយមានការប្រលាក់ប្រឡូកពីខាងក្រៅ**
  - ➢ ដាំដំណាំធ្វើជារបង ឬទុកដីចំនេរការពារជុំវិញចំការ

- **ការដាំដុះដែលមានលក្ខណៈពឹងពាក់លើខ្លួនឯង**
  - ➢ ផលិតកម្ម ឬការដាំដុះដោយប្រើប្រាស់សារធាតុដែលអាចរកបាននៅក្នុងចំការ ឬក្នុងភូមិ

# បមណនីយ (ខ្នាតគំរូ) កសិកម្មសរីរាង្គ

## [Organic Agriculture Standards]

២០០៣

ពង្រាង

*រៀបចំ ដោយ អង្គការស្រែខ្មែរ*

*យកលំនាំតាម ACT Organic Agriculture standards, Thailand, May 2001,* និង *FOOD Link, Vietnam Association for basic Organic Agricultural standard, production and processing, July 1999.*

---

## គោលការណ៍ទូទៅក្នុងការដាំដំណាំសរីរាង្គ ការកែច្នៃ ការទុកដាក់ និងការដឹកជញ្ជូន

កសិកម្មសរីរាង្គ គឺជាដំណើរនៃការដាំដុះតាមបែបធម្មជាតិ ឬតាមបែបកសិកម្មអេកូឡូស៊ី ដែលមានគោលការណ៍ជាមូលដ្ឋានគ្រឹះដូចតទៅនេះ :

- ថែរក្សាប្រព័ន្ធអេកូឡូស៊ីក្នុងការដាំដុះ
  - មិនប្រើសារៈធាតុគីមីសំយោគ និង GMOs
  - ការពារការហូរច្រោះ ឬការបាត់បង់ដីជាតិដី ស្រទាប់ខាងលើ
- ធ្វើអោយប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីក្នុងការដាំដុះ
  - កែលំអសារធាតុចិញ្ចឹមក្នុងដី តាមរយៈការប្រើប្រាស់ជីកំប៉ុស្ត៍ និងសារធាតុសរីរាង្គផ្សេងៗទៀត
  - ថែរក្សាជីវសាស្ត្រចំរុះរបស់ចំការ
- ធ្វើការដោយសុខដុម ជាមួយដំណើរវិវត្តន៍របស់ប្រព័ន្ធអេកូឡូស៊ីក្នុងចំការ
  - ថែរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ី ដែលនាំអោយមានការកើនឡើងនូវសត្វមានប្រយោជន៍
  - បង្កើនការចាប់យកសារធាតុអាហ្សូតដោយធម្មជាតិ
  - ការដាំដំណាំចំរុះ និងដំណាំបង្វិល
- ការពារកុំអោយមានការប្រលាក់ប្រឡូកពីខាងក្រៅ
  - ដាំដំណាំធ្វើជារបង ឬទុកដីទំនេរការពារជុំវិញចំការ
- ការដាំដុះដែលមានលក្ខណៈពឹងពាក់លើខ្លួនឯង
  - ផលិតកម្ម ឬការដាំដុះដោយប្រើប្រាស់សារធាតុដែលអាចរកបាននៅក្នុងចំការ ឬក្នុងភូមិ

## ១. ការគ្រប់គ្រងទូទៅនៃចំការដំណាំសរីរាង្គ :

*<u>គោលការណ៍ទូទៅ :</u>*

ការគ្រប់គ្រងចំការត្រូវផ្អែកទៅលើវដ្ត និងដំណើរការជាធម្មជាតិរបស់ជីវសាស្ត្រចំរុះ និងសារធាតុចិញ្ចឹម ។ ការប្រើប្រាស់សារធាតុ ឬសំភារៈទាំងឡាយណាដែលរំខាន ឬប៉ះពាល់ដល់វដ្ត និងដំណើរការនេះ ត្រូវបានហាមឃាត់ ។

*<u>ខ្លាតតំរូវ :</u>*

១.១. ហាមឃាត់នូវការប្រើប្រាស់ សារធាតុគីមីសំយោគគ្រប់ប្រភេទ ដោយបូករួមទាំងជីគីមី ថ្នាំគីមីពុល និងអ័រម៉ូន

១.២. ហាមឃាត់ការប្រើប្រាស់សារៈធាតុពន្ធុបំលែង (GMO) ទាំងក្នុងផលិតកម្ម ការវិចខ្ចប់ និងការទុកដាក់ ។

១.៣. ឧបករណ៍បាញ់ថ្នាំ ដែលប្រើក្នុងការដាំដុះតាមបែបគីមី មិនអនុញ្ញាតិអោយប្រើប្រាស់នៅក្នុងចំការដំណាំសរីរាង្គឡើយ ។

១.៤. ក្នុងករណីមានការប្រើប្រាស់ម៉ាស៊ីនច្រូតកាត់ ឬម៉ាស៊ីនបោកបែនរួម ផលិតករត្រូវតែសំអាតម៉ាស៊ីនអោយបានស្អាត មុននឹងយកវាមកប្រើប្រាស់ក្នុងចំការដំណាំសរីរាង្គ ។

១.៥. ផលិតករត្រូវតែកត់ត្រានូវរាល់ចំណូល និងចំណាយទាំងអស់ ដែលទាក់ទងទៅនឹងចំការដំណាំសរីរាង្គនេះ ដោយកត់សំគាល់អំពីប្រភពសំភារៈសំរាប់ប្រើប្រាស់ គុណភាព និងទិន្នន័យនៃការលក់ដូរជាដើម ។

១.៦. ក្នុងករណីដែលផលិតករ មិនបានប្តូរចំការទាំងមូលរបស់គេ អោយទៅជាការដាំដុះតាមបែបសរីរាង្គទេ នោះចំណែកដីសំរាប់ដាំដំណាំសរីរាង្គ ត្រូវតែខ័ណ្ឌចែកដាច់ពីគ្នាយ៉ាងច្បាស់លាស់ ហើយចំការទាំងអស់ត្រូវតែអនុញ្ញាតិអោយគណកម្មាធិការឯករាជ្យ ធ្វើការពិនិត្យពិច័យ និងវាយតំលៃយ៉ាងច្បាស់លាស់ ។

១.៧. ប្រសិនបើមានការផ្លាស់ប្តូរទំហំផលិតកម្ម គិតរួមទាំងការបង្កើន ឬបន្ថយទំហំចំការ ការផ្លាស់ប្តូរមុខដំណាំដាំដុះ ជាដើម នោះផលិតករ ត្រូវតែជូនដំណឹងមកអង្គការស្រែខ្មែរ ជាបន្ទាន់ ។

១.៨. ការកាប់រានព្រៃឈើ ដើម្បីប្រកបរបរចំការដំណាំសរីរាង្គ ត្រូវបាន ហាមឃាត់ ។

១.៩. ដីចំការ ដែលបានចុះបញ្ជីសំរាប់ការដាំដំណាំសរីរាង្គ មិនត្រូវធ្វើការត្រឡប់ទៅ ត្រឡប់មក ជាមួយការដាំដំណាំដោយពឹងផ្អែកលើគីមីឡើយ ។ អង្គការស្រែខ្មែរ នឹងមិនចុះបញ្ជីសំរាប់ដីចំការថ្មី ប្រសិនបើការបោះបង់ចោលចំការដំណាំសរីរាង្គចាស់ មិនមានហេតុផលច្បាស់លាស់ ។

១.១០. ប្រភេទដំណាំ និងពេលវេលានៃការដាំនៅលើចំការដំណាំសរីរាង្គ មិនត្រូវអោយដូចទៅនឹងការដាំដុះនៅចំការធម្មតាដទៃទៀតឡើយ ។

១.១១. ការដាំដំណាំប្រភេទដូចគ្នាអាចអនុញ្ញាតិអោយបាន តែក្នុងករណីដែលផលិតករ បានបញ្ជាក់យ៉ាងច្បាស់លាស់ អំពីគំរោងផលិតកម្ម គឺត្រូវមានថ្ងៃខែដាំដុះ និងការប្រមូលផលខុសពេលគ្នា ហើយការកត់ត្រាចំណាយ-ចំណូល ក៏ត្រូវតែធ្វើអោយដាច់ដោយឡែកពីគ្នាដែរ ។

១.១២. នៅពេលដែលចំការដំណាំសរីរាង្គនៅជាប់នឹងចំការដាំដុះតាមបែបគីមីធម្មតា ផលិតករត្រូវតែបង្កើតតំបន់ ការពារពីការឆ្លងធាតុគីមីទាំងឡាយ ដែលអាចកើតមានឡើង ។ តំបន់ការពារនេះ យ៉ាងហោចណាស់ក៏ត្រូវ តែមានទទឹង ១ម ដែរ ជាមួយការដាំដំណាំក្នុងស្រុកទាំងឡាយណា ដែលធន់ទ្រាំទៅនឹងសត្វល្អិតបំផ្លាញ និងជំងឺ ។ ដំណាំដែលដាំនៅលើ

តំបន់ការពារនេះ មិនអាចលក់បញ្ចូលជាមួយនឹងផលិតផលសរីរាង្គឡើយ ដូច្នេះដំណាំដែលយកមកដាំសំរាប់ធ្វើជារបងការពារនេះ ត្រូវតែមានប្រភេទផ្សេងដាច់ពីគ្នាទៅនឹងដំណាំដែលដាំ សំរាប់ចំការដំណាំសរីរាង្គ ។ ប្រសិនការឆ្លងនេះអាចកើតមានឡើងតាមរយៈទឹកហូរ នោះម្ចាស់ចំការត្រូវ អោយជីក ប្រឡាយមួយខ័ណ្ឌដាច់ដោយឡែក ពីប្រភពទឹកហូរនេះ ធ្វើយ៉ាងណាដោយមិនអនុញ្ញាតិអោយ ទឹកនេះ ហូរចូលក្នុងចំការ ឬស្រែដំណាំសរីរាង្គឡើយ ។

១.១៣. ក្នុងករណីដែលពិនិត្យឃើញថា ការឆ្លងពីខាងក្រៅមានលក្ខណៈធ្ងន់ធ្ងរខ្លាំង ទាំងតាមខ្យល់ និងតាមប្រភពទឹក ផលិតផលនោះ នឹងមិនអនុញ្ញាតិអោយលក់ជាផលិតផលសរីរាង្គឡើយ ។ ក្នុងករណីនេះ ផលិតករត្រូវទទួលខុសត្រូវដោយខ្លួនឯងក្នុងការខាតបង់ទាំងនេះ ។

១.១៤. ផលិតករត្រូវតែថែរក្សា និងយកចិត្តទុកដាក់អំពីជីវសាស្ត្រចំរុះ នៅក្នុងចំការដំណាំសរីរាង្គ ដោយយ៉ាងហោចណាស់ទុកដីមួយផ្នែករបស់ចំការ ក្នុងទំហំមិនតិចជាង ៥% នៃផ្ទៃចំការទាំងមូល អោយនៅទំនេរសំរាប់ជាជំរករបស់ជីវៈសាស្ត្រចំរុះផ្សេងៗ ទាំងរុក្ខជាតិ និងសត្វនានា ។ ដីមួយផ្នែកនេះអាចជា ដីព្រៃរបោះ ព្រៃលិចទឹក ដំណាំឈើហូបផ្លែចំរុះ ចំការស្មៅកក់នៅតាមជាយចំការ ដើមឈើផ្សេងៗ ស្រះត្រី ពីធម្មជាតិ ប្រឡាយឬស្នាមភ្លោះពីធម្មជាតិ ឬតំបន់ទុកចោលដែលមានដុះរុក្ខជាតិ ជាធម្មជាតិ ជាដើម ។

១.១៥. នៅក្នុងផលិតកម្មដំណាំប្រចាំឆ្នាំ ផលិតករត្រូវតែអនុវត្តន៍ការដាំដំណាំបង្វិល (ដូរមុខដំណាំទៅលើដីដដែល) ដើម្បីកាត់បន្ថយការរាលដាលរបស់ជំងឺដំណាំ សត្វល្អិត និងស្មៅចង្រៃផ្សេងៗ ។ ដំណាំអំបូរសណ្តែក ត្រូវដាំ ជាដំណាំបង្វិលនេះ ដើម្បីជួយកែលំអ សារធាតុសរីរាង្គ និងជីជាតិ របស់ដី ។

## ២. រយៈពេលប្តូរពីចំការដាំដុះតាមបែបគីមី នៅការដាំដុះដំណាំសរីរាង្គ :

*គោលការណ៍ទូទៅ :*

- កសិកម្មសរីរាង្គ គឺជាដំណើរការដែលអភិវឌ្ឍន៍ទៅរកភាពអាចសំរេចបាន និងមាននិរន្តភាពនៃប្រព័ន្ធអេកូស្ទេមបរិស្ថាន ។ រយៈពេលនៃការចាប់ផ្តើម រហូតដល់ពេលមានលិខិតបញ្ជាក់ នៃចំការដំណាំ ត្រូវបានកំណត់ថា ជារយៈពេលផ្លាស់ប្តូរ ។
- ចំការដំណាំទាំងមូល គួរតែត្រូវបានផ្លាស់ប្តូរ អោយត្រូវតាមខ្នាតគំរូមួយ ដោយឆ្លងកាត់រយៈពេលជាក់លាក់មួយ ។

*ខ្នាតគំរូ :*

២.១. ចំការដំណាំដាំតាមបែបគីមីទាំងអស់ ដែលនឹងទទួលបានលិខិតបញ្ជាក់ជាចំការដំណាំសរីរាង្គ ត្រូវឆ្លងកាត់រយៈពេលផ្លាស់ប្តូរមួយ ។ ក្នុងរយៈពេលនេះ ម្ចាស់ចំការត្រូវចាប់ផ្តើមអនុវត្តន៍ទៅតាមខ្នាតគំរូនៃ ការដាំដុះតាមបែបសរីរាង្គនេះ ។ ផលិតផលដែលប្រមូល ពីចំការនេះ មិនអនុញ្ញាតិអោយលក់ជា ផលិតផលសរីរាង្គឡើយ ។ ទៅតាមស្ថានភាព និងប្រវត្តិរបស់ចំការ រយៈផ្លាស់ប្តូរនេះ យ៉ាងហោចណាស់ក៏ត្រូវមានរយៈពេលពី ៦-១២ ខែ ដែរ ។

២.២. រយៈពេលនេះអាចនឹងត្រូវបន្តយូរជាងនេះ ប្រសិនបើមានភស្តុតាងបញ្ជាក់ពីភាពក្រខ្វក់របស់ចំការ ដោយសារមានការប្រើប្រាស់សារធាតុគីមីជាយូរឆ្នាំមកហើយ ។

២.៣. ការបញ្ជាក់អោយដាក់បញ្ចូលចំការទាំងមូល ឬផ្នែកមួយនៃចំការ ទៅជាចំការដំណាំសរីរាង្គ ត្រូវធ្វើឡើងនៅក្រោយមានការត្រួតពិនិត្យលើកទីមួយ ដោយក្រុមសើបអង្កេតឯករាជមួយសំរាប់ការត្រួតពិនិត្យប្រព័ន្ធខាងក្នុង ។

## ៣. ប្រភេទ និងពូជដំណាំ :

៣.១. ព្យាយាមជ្រើសរើសប្រភេទ និងពូជដំណាំណា ដែលសមស្របទៅនឹងស្ថានភាពអេកូឡូស៊ីនៅក្នុងតំបន់ និងមានភាពធន់ទ្រាំទៅនឹងសត្វល្អិតចង្រៃ និងជំងឺផ្សេងៗ ។

៣.២. គ្រាប់ពូជ និងដើមដំណាំដែលយកមកដាំដុះ ត្រូវតែជាផលិតផលក្នុងស្រុក ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការទិញគ្រាប់ពូជ ឬដើមដំណាំពីខាងក្រៅ (ពីផ្សារ) អាចអនុញ្ញាតិបាន ចំពោះចំការដំណាំសរីរាង្គដែលទើបតែអភិវឌ្ឍន៍ដំបូង ។ រយៈនេះអាចពន្យាយ៉ាងយូរបំផុតរយៈពេល ១០ឆ្នាំ ផលិតករត្រូវតែ ផលិត ឬស្វែងរកគ្រាប់ពូជដែលអាចផលិតបានដោយខ្លួនឯង ឬការដោះដូរពីចំការដំណាំសរីរាង្គរបស់ផលិតករផ្សេង ។

៣.៣. ពូជដំណាំ ផលិតមកពី GMO មិនត្រូវបានអនុញ្ញាតិឡើយ ។

## ៤. ការគ្រប់គ្រងដី ទឹក និងជី :

*គោលការណ៍ទូទៅ:*

- បរិមាណសមស្របនៃសំភារៈទាំងសត្វ និងរុក្ខជាតិ ដែលដកយកចេញពីចំការ គួរតែដាក់បន្ថែមវាទៅក្នុងដីចំការវិញ ដើម្បីបង្កើន ឬយ៉ាងហោចណាស់ ថែរក្សាជីជាតិដី និងសកម្មភាពជីវសាស្ត្រនៅក្នុងបរិស្ថានចំការដំណាំ ។
- គួររក្សា pH របស់ដីសមស្របសំរាប់ប្រភេទដំណាំផ្សេងៗ ដោយបន្ថែមកំបោរ ដីល្បាប់ ផេះ ឬអាចម៍រណា ជាដើម
- មិនត្រូវទុកដីចំការអោយនៅទំនេរឡើយ ដោយត្រូវដាំដំណាំពពួកសណ្តែកជាគំរប
- ដំណាំពពួកសណ្តែក ត្រូវបានណែនាំអោយប្រើនៅមុនពេល ឬក្រោយប្រមូលផលដំណាំសំខាន់ ប្រៀបដូចជាដំណាំបង្វិល
- ជៀសវាង ឬកាត់បន្ថយការប្រើប្រាស់គ្រឿងម៉ាស៊ីនធុនធំៗ ដែលអាចធ្វើអោយដីហាប់
- ប្រសិនបើអាច ដីចំការ និងទឹកដែលប្រើប្រាស់សំរាប់ដំណាំចំការសរីរាង្គ គួរតែត្រូវបានយកមកវិភាគជាប្រចាំ ។

*ខ្នាតគំរូ:*

៤.១. ផលិតករគួរតែព្យាយាមប្រើប្រាស់សារធាតុសរីរាង្គ ពីរុក្ខជាតិ និងសត្វដែលផលិតចេញពីចំការរបស់ខ្លួន ឬអាចរកបាននៅក្នុងភូមិ សំរាប់ការកែលំអគុណភាពដី នឹងព្យាយាមកាត់បន្ថយការប្រើប្រាស់សារធាតុសរីរាង្គដែលយកមកពីខាងក្រៅ ហើយដែលអាចអនុញ្ញាតិអោយប្រើបានតែក្នុងករណីសារធាតុទាំងនេះមិនអាចរកបាន នៅក្នុងចំការខ្លួនឯង ឬក្នុងភូមិតែប៉ុណ្ណោះ ។

៤.២. ផលិតករត្រូវរៀបចំគំរោងផលិតជីសរីរាង្គចំរុះ សំរាប់ទុកប្រើប្រាស់ ។ ការប្រើប្រាស់ជីសរីរាង្គត្រូវធ្វើឡើងតាមភាពចាំបាច់ និងទៅតាមបរិមាណសមស្របដោយផ្តោតការយកចិត្តទុកដាក់ទៅលើតុល្យភាពជីជាតិរបស់ ដី និងតំរូវការរបស់ដំណាំ ។

៤.៣. មានតែប្រភេទជីសរីរាង្គ ដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ទី ១ ប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតិអោយប្រើ ។

៤.៤. ជីដែលមិនមានបរិយាយនៅក្នុង ឧបសម្ព័ន្ធ ទី ១ អាចអនុញ្ញាតិអោយប្រើប្រាស់តែបន្ទាប់ពីមានការបញ្ជាក់ដោយផ្អែកទៅតាមគោលការណ៍សំរាប់ការវាយតំលៃបន្ថែមទៅលើ សំភារៈប្រើប្រាស់ ដូចមានចែងនៅក្នុង ឧបសម្ព័ន្ធ ទី ២ ។

៤.៥. លាមកសត្វស្រស់មិនត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ជាដាច់ខាត លើកលែងតែវាត្រូវបានបំលែងទៅជា កំប៉ុស្តិ៍រួចហើយ ឬក្រោយពេលហាលសំងួតឬក៏ត្រូវបានលាយទៅក្នុងដី យ៉ាងហោចណាស់ ១ខែមុនពេលដាំដំណាំ ។

៤.៦. សារធាតុសរីរាង្គ ដែលមានលាយកាកសំណល់លាមកមនុស្ស មិនត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ជាដាច់ខាត ។

៤.៧. ជីអាចម៍មាន់ ដែលបានពីរោងចិញ្ចឹមមាន់តាមបែបគីមី មិនអនុញ្ញាតិអោយប្រើឡើយ ។

៤.៨. ជីកំប៉ុស្តិ៍ដែលផលិតខ្លួនឯង និងជីកំប៉ុស្តិ៍ដែលទិញពីខាងក្រៅ គឺត្រូវបានជំរុញអោយប្រើ ប៉ុន្តែជីកំប៉ុស្តិ៍ទាំងនេះ ត្រូវតែផលិតឡើងដោយប្រើសារធាតុសរីរាង្គដែលមានរាយឈ្មោះនៅក្នុង ឧបសម្ព័ន្ធទី ១ (ផ្នែកទ ១) ។
ផលិតករត្រូវតែកត់ត្រា និងរាយការណ៍អោយបានច្បាស់ពីប្រភពសារៈធាតុសរីរាង្គ និងប្រភពជីកំប៉ុស្តិ៍នេះ ។

៤.៩. ជីខនិជ ដូចជារ៉ែថ្ម ផូស្វាត អាចប្រើបានទៅក្នុងផលិតកម្មជីកំប៉ុស្តិ៍ ដើម្បីបង្កើនបរិមាណសារៈធាតុចិញ្ចឹម ។

៤.១០. ផលិតផលសរីរាង្គចេញពីកាកសំណល់រោងចក្រ អាចប្រើបានទៅក្នុងការផលិតជីកំប៉ុស្តិ៍ ប៉ុន្តែផលិតករ ត្រូវតែជូនដំណឹងអោយបានច្បាស់ មកអង្គការស្រែខ្មែរ ពីប្រភពសារៈធាតុទាំងនេះ ដើម្បីធ្វើការពិនិត្យបន្ថែម ។

៤.១១. កាកសំណល់ចេញពីទីក្រុង មិនអនុញ្ញាតិអោយប្រើឡើយ ដោយសារកាកសំណល់ទាំងនេះ មានផ្ទុកសារៈធាតុ និងលោហធាតុជាច្រើនប្រភេទ ដែលអាចធ្វើអោយប៉ះពាល់ដល់សុខភាពមនុស្ស ។

៤.១២. ជីខនិជ អាចនឹងត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ជាជំនួយបន្ថែម នៅពេលណាដែលចាំបាច់ ជាពិសេសនៅកន្លែងដែលមានកង្វះខាតនៃវត្ថុជីជាតិដី ខ្វះដំណាំពពួកសណ្តែក និងសារៈធាតុសរីរាង្គផ្សេងៗទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ ជីខនិជនេះត្រូវតែផលិតឡើងក្នុងទំរង់ជាធម្មជាតិ (ដោយគ្រាន់តែកិនថ្មផ្ទាល់) ។ ជីខនិជដែលសំយោគដោយការប្រើសារៈគីមីបន្ថែម មិនត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ឡើយ ។

៤.១៣. ក្នុងករណីចាំបាច់ ផលិតករ នឹងត្រូវបានប្រាប់អោយធ្វើការវិភាគជីកំប៉ុស្តិ៍ ឬជីខនិជដែលទិញពីខាងក្រៅ មុននឹងមានការអនុញ្ញាតិអោយប្រើប្រាស់ ។

៤.១៤. អនុញ្ញាតិអោយប្រើប្រាស់ពពួកមីក្រូសារពាង្គកាយផ្សេងៗដើម្បីកែលំអដី ពន្លឿនការផលិតជីកំប៉ុស្តិ៍ ការសំអាតកាកសំណល់ ឬទឹក ទៅក្នុងការដាំដុះដំណាំសរីរាង្គ ប៉ុន្តែពពួកមីក្រូសារពាង្គកាយទាំងឡាយណា ដែលផលិតចេញពី GMO មិនត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ឡើយ ។

៤.១៥. ហាមមិនអោយដុតកាកសំណល់រុក្ខជាតិ (ដំណាំ) មុននឹងយកទៅប្រើប្រាស់ ព្រោះវាអាចបណ្តាលអោយបាត់បង់សារធាតុសរីរាង្គ និងពពួកមីក្រូសារពាង្គកាយជាច្រើន លើកលែងតែក្នុងករណីចាំបាច់ជាក់ស្តែងដូចជា ការការពារការឆ្លងរាលដាលដ៏ខ្លាំងក្លានៃពពួកសត្វល្អិត និងជំងឺដំណាំផ្សេងៗ ។

៤.១៦. ផលិតករត្រូវតែវាស់វែង និងកំរិតការប្រើប្រាស់ប្រភពទឹកដ៏ច្រើនលើសលប់ ។

៤.១៧. ប្រសិនបើអាច ផលិតករគួរតែធ្វើការវិភាគដីចំការរបស់គេ ដើម្បីការពារភាពអាល់កាឡាំង (ការឡើង ប្រៃ) នៃដី ។

៤.១៨. សារធាតុអ័រម៉ូន ការប្រើប្រាស់ថ្នាំពន្លឿនការលូតលាស់ ល័ក្ខពណ៌ ឬថ្នាំស្ងួយ ដើម្បីផ្លូវពណ៌ផលិតផលដំណាំ ឬពន្លឿនការទុំរបស់វា មិនត្រូវបានហាមឃាត់ ។ មានតែសារធាតុអ័រម៉ូន ដែលបានរាយនាម នៅក្នុងឧបសម្ព័ន្ធទី ១ (ផ្នែកទី២) តែប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតិអោយប្រើ ។

## ៥. ការការពារ និងការកំចាត់ ចង្រៃដំណាំ សត្វល្អិត និងស្មៅចង្រៃ :

<u>*គោលការណ៍ទូទៅ*</u>:

- លើកដំកើងការសាយភាយនៃពពួកសត្វមានប្រយោជន៍ តាមរយៈការដាំផ្ការផ្សេងៗ ធ្វើជាដំណាំរួមផ្សំ ដាំរុក្ខជាតិផ្សេងៗ ធ្វើជាជំរករបស់វា ឬការធ្វើសំបុកសំរាប់ចាបស្នាក់នៅជាដើម
- ដាំលាយ (ចំរុះ) ដំណាំ ដែលអាចដេញសត្វល្អិត អាចជួយកាត់បន្ថយការខូចខាតដោយសារការស៊ីបំផ្លាញ របស់វា ដូចជាដាំពពួកដំណាំស្លែលាយចំរុះជាមួយពពួកខ្ទឹម ឬស្លឹកគ្រៃជាមួយពពួកខាតណាជាដើម ។
- ចៀសវាងការដាំដំណាំប្រភេទដដែលឡើងវិញនៅលើចំការដដែល ដើម្បីកាត់បន្ថយការខូចខាតដោយសារ សត្វល្អិតបំផ្លាញ ។ ផលិតករត្រូវអនុវត្តន៍ការដាំដំណាំ ឆ្លាស់ ឬបង្វិល ។
- ទំលាប់នៃការដាំដុះល្អអាចជួយការពារការដុះរាលដាលរបស់ស្មៅ ដូចជាការភ្ជួរដី ការដាំដំណាំបង្វិល ការដាំដំណាំលាយចំរុះ ការដាំដំណាំគំរបដី និងការគ្របដីដោយប្រើចំបើង ឬស្លឹកឈើផ្សេងៗជាដើម ។

<u>*ខ្នាតគំរូ*</u> :

៥.១. ហាមឃាត់មិនអោយប្រើប្រាស់ផលិតផលគីមីសំយោគ ដូចជាថ្នាំពុល ឬ GMO ដើម្បីបាញ់ការពារដំណាំ ។

៥.២. មានតែវិធីសាស្ត្រប្រើ និងសារធាតុដែលបានរាយឈ្មោះនៅក្នុង ឧបសម្ព័ន្ធទី ១ តែប៉ុណ្ណោះដែលអាចអនុញ្ញាតិ អោយប្រើប្រាស់បាននៅក្នុងការការពារដំណាំ ។

៥.៣. វិធីសាស្ត្រប្រើ និងសារធាតុក្រៅពីនេះ ប្រហែលជាអាចអនុញ្ញាតិអោយប្រើប្រាស់បាននៅក្រោយពេលការ វាយតំលៃរួមមួយផ្អែកទៅតាមគោលការណ៍នៃការវាយតំលៃ ដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ២ ។

៥.៤. ហាមមិនអោយប្រើថ្នាំដក់ស្រស់ ។ ទឹកត្រាំពីថ្នាំជក់អាចប្រើប្រាស់បាន តែការប្រើប្រាស់ត្រូវបញ្ជាក់ថាមិនមានប៉ះពាល់ដល់សត្វមានប្រយោជន៍ផ្សេងៗទៀត ។

៥.៥. ហាមមិនអោយប្រើម្សៅសាប៊ូ ឬសារៈសំយោគគីមីស្អិតផ្សេងៗឡើយ ។

៥.៦. វិធានការជីវៈសាស្ត្រ និងការចាប់ដោយដៃត្រូវបានលើកទឹកចិត្តអោយប្រើ ប៉ុន្តែត្រូវតែប្រយ័ត្នប្រយែងការប៉ះពាល់ដល់ពពួកសត្វមានប្រយោជន៍ផ្សេងៗនៅក្នុងចំការ ។

៥.៧. កៅស៊ូផ្លាស់ស្ទិចអាចប្រើបានសំរាប់គ្របរងដំណាំដើម្បីការស្មៅ ប៉ុន្តែការដុតកៅស៊ូនៅក្នុងចំការ ត្រូវបានហាមឃាត់ ។

## ៦. ផលិតផលព្រៃ :

៦.១. ផលិតផលព្រៃ គឺជាផលិតផល (ដូចជាផ្សិត ជីផ្សេងៗ ទឹកឃ្មុំ ជាដើម) ដែលប្រមូលបានពីព្រៃ ធម្មជាតិ ។ ផលិតផលទាំងនេះត្រូវតែប្រមូលពីតំបន់មួយច្បាស់លាស់ ដែលពុំមានការប្រឡាក់ដោយសារធាតុគីមី ពីចំការព័ទ្ធជុំវិញ។

៦.២. ផលិតផលព្រៃ ត្រូវប្រមូលពីតំបន់ដែលពុំមានការប្រើប្រាស់សារធាតុគីមី យ៉ាងហោចណាស់ ក៏រយៈពេល២ឆ្នាំ ដែរ ។

៦.៣. ការប្រមូលផល ពីផលិតផលទាំងនេះ មិនត្រូវអោយមានឥទ្ធិពលទៅលើបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីនៅតំបន់នោះឡើយ ដោយគិតទាំងពីលទ្ធភាពនៃការបាត់បង់ ធនធានពូជចំរុះ (ទាំងរុក្ខជាតិ និងសត្វ) ។

## ៧. ការប្រមូលផល ការកែច្នៃ ការវេចខ្ចប់ និងការដឹកជញ្ជូន :

៧.១. ដំណើរការគ្រប់ដំណាក់នៃការប្រមូលផល ការកែច្នៃ ការវេចខ្ចប់ និងការដឹកជញ្ជូន ត្រូវតែមានការត្រួតពិនិត្យ និងបញ្ជាក់យ៉ាងច្បាស់លាស់ ពីក្រុម អធិការចិក្ខ ឯករាជ្យមួយ ។

៧.២. ដំណើរការទាំងនេះ ត្រូវតែបានកត់ត្រាយ៉ាងច្បាស់លាស់ដោយអ្នកទទួលខុសត្រូវណាម្នាក់ ។

៧.៣. ក្នុងករណីដែលមានការជួលបន្ត ឬធ្វើកិច្ចសន្យាទៅនរណាម្នាក់សំរាប់ទទួលខុសត្រូវការងារនេះ ជននោះត្រូវតែបានបង្រៀនយ៉ាងច្បាស់ និងយល់អំពីខ្នាតគំរូនេះ ។

៧.៤. គ្រប់ដំណាក់កាលទាំងអស់ ការលាយផលិតផលពីចំការដំណាំសរីរាង្គ និងចំការធម្មតា មិនអាចទទួលយក បានឡើយ ។

៧.៥. សំភារៈសំរាប់ធ្វើការវេចខ្ចប់ គួតែជាវត្ថុអាចរកបានជាធម្មជាតិ ដោយព្យាយាមកាត់បន្ថយសំភារៈទាំងឡាយណាដែលអាចបណ្តាលអោយមានការប៉ះពាល់ដល់បរិស្ថាន ។ កាកសំណល់ពីការវេចខ្ចប់ គួតែត្រូវបានប្រើប្រាស់ឡើងវិញ ។

៧.៦. ការប្រើប្រាស់សំបកបាវ ឬកញ្ចប់ដែលបានដាក់សារៈធាតុគីមី (សំបកបាវជីគីមី ឬសំបកធុងថ្នាំ) មិនអនុញ្ញាតិអោយយកខ្ចប់ផលិតផលសរីរាង្គ ទាំងនេះឡើយ ទោះបីមានការលាងសំអាត យ៉ាងណាក៏ដោយ ។

៧.៧. ហាមមិនអោយប្រើសារៈធាតុគីមីផ្សេងៗ នៅក្នុងការទុកដាក់ ដោយគិតទាំងផលិតផលដែលប្រមូលបានពីចំការ សរីរាង្គ និងការថែរក្សាទុកសំរាប់លក់បន្ត ឡើយ ។

៧.៨. ការដឹកជញ្ជូនផលិតផលសរីរាង្គ អាចធ្វើជាមួយផលិតផលពីចំការធម្មតាបាន ប៉ុន្តែត្រូវតែមានការខ័ណ្ឌដាច់ពីគ្នាយ៉ាងជាក់លាក់ ។

## ៨. សមភាពសង្គម :

*__គោលការណ៍ណែនាំទូទៅ :__*

- សមធមិ និងសមភាពសង្គម គឺជាផ្នែកមួយនៅក្នុងផលិតកម្ម និងការកែច្នៃកសិកម្មសរីរាង្គ

*__ខ្នាតគំរូ:__*

៨.១. ក្រុមកសិករអ្នកផលិត គួតែត្រូវបានរៀបចំ និងចងក្រងឡើងតាមគោលការណ៍ប្រជាធិបតេយ្យ ជាមួយនិងភាពស្មើគ្នានៅក្នុងការចូលរួម និងមានឱកាសសំរាប់សមាជិកទាំងអស់ ។

៨.២. នៅក្នុងផលិតកម្ម និងការកែច្នៃ ដែលមានការប្រើប្រាស់ដោយកំលាំងពលកម្ម គួតែមានការទូទាត់ជាប្រាក់បំណាច់មួយសមស្រប ជាសវៀង ការកេងប្រវាញ់លើកំលាំងពលកម្មអ្នកដទៃ ។

## ឧបសម្ព័ន្ធទី ១. បញ្ជីរាយមុខសំភារៈ និងវិធីសាស្ត្រប្រើ ដែលអនុញ្ញាតនៅក្នុងផលិតកម្មសរីរាង្គ

*សំគាល់ :* √: *អនុញ្ញាតិ* ! : *ប្រើដោយមានការប្រុងប្រយ័ត្ន ដូចមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធនេះ*

### ផ្នែកទី១. សំភារៈប្រើសំរាប់ធ្វើជាជី និងកែលំអដី :

| សំភារៈ | សំគាល់ | បរិយាយ/លក្ខណៈ |
|---|---|---|
| ឆ្អឹងចេញពីកាកសំណល់អាហារ | ! | • ឆ្អឹងសត្វ ឬត្រី ប្រើជាប្រភពសំរាប់បង្កើន P និង K នៅក្នុងដី<br>• អាចធ្វើដី ក្លាយជាអាល់កាឡាំងបន្តិច បន្តួច |
| ទឹករង្វចេញពីស្ករ អំពៅ ឬស្ករត្នោត | √ | ប្រើនៅក្នុងការធ្វើជីកំប៉ុស្តិ៍ពីស្លឹកស្រស់ សំរាប់បង្កើនចំណើពពួកមីក្រុប |
| កាកសំណល់គ្រាប់រុក្ខជាតិ ក្រោយពីច្រឹនំ | ! | កាកសំណល់សារធាតុសរីរាង្គ ក្រោយចំរាញ់យកប្រេង ដូចជាសណ្តែកដី ស្តៅ សណ្តែកសៀង ។ សារធាតុទាំងនេះសំបូរទៅដោយ N និងប្រើល្អ នៅក្រោយវាក្លាយជាជីកំប៉ុស្តិ៍ ។ ការប្រើប្រាស់ស្រស់ អាចធ្វើឱ្យខូចដំណាំ |
| អង្កាម | ! | ប្រើល្អសំរាប់ក្រាលគ្របលើថ្នាល ។ អាចប្រើដើម្បីកែលអដីអិដ្ឋ ប៉ុន្តែគួលាយវាជាមួយសារធាតុផ្សេងទៀត ព្រោះវាមានសារធាតុចិញ្ចឹមតិច និង មានចលនាយឺតៗ មុននឹងក្លាយជាកំប៉ុស្តិ៍ |
| កាកសំណល់រោងចក្រឧស្សាហកម្ម | ! | អាចប្រើក្នុងការធ្វើជីកុំប៉ុស្តិ៍ ប៉ុន្តែត្រូវតែពិនិត្យពីប្រភពអោយបានច្បាស់ |
| អាចម៍រណាឈើ | ! | ប្រើលាយដោយផ្ទាល់ជាមួយដី ដើម្បីកែលំអចលនាខ្យល់ និងសមត្ថភាពចាប់ទឹករបស់ដី ប៉ុន្តែមានភាពយឺតៗក្នុងការបំលែងជាកំប៉ុស្តិ៍ |
| ផេះអុសឈើ | ! | ប្រើដើម្បីបង្កើន pH របស់ដី និងជាប្រភព P និង K ប៉ុន្តែហាមប្រើជាមួយកូនដំណាំ មុនដកយកទៅស្ទូង |
| មីក្រូសារពាង្គកាយ | √ | លើកលែងតែ GMOs |
| ថ្មកំបោរ | √-! | ប្រើដេម្បីបង្កើន pH ដី ប៉ុន្តែការប្រើច្រើនអាចធ្វើអោយទៅជាពុលដី |
| កាកសំណល់ពីការផលិតផ្សិតចំបើង | √ | ប្រើល្អសំរាប់កែលំអទំរង់ដី និងជីជាតិក្នុងដី |
| ជីភាវ (ជីជីវសាស្ត្រ) | √ | សារធាតុផ្សំដែលមានពួកមីក្រូសារពាង្គកាយ ជួយក្នុងការបំបែកសារធាតុ ចិញ្ចឹមសំរាប់អោយឫសដំណាំងាយចាប់យកបាន |
| ជីមីក្រូធាតុ | ! | សារធាតុចិញ្ចឹមសំយោគដូចជា ស្ពាន់ធ័រ ទង់ដែង ប្រាក់ ប័រ ម៉ាញេស្យូម ស័ង្កសី ម៉ូលីបដែន ដែក អ៊ីយ៉ូត ជាដើម ត្រូវបានអនុញ្ញាតិអោយប្រើ តែនៅក្នុងករណីចាំបាច់ដោយមានការលេចចេញនូវសញ្ញាខ្វះសារធាតុទាំងនេះ |
| ជីស្លឹកឈើ | √ | ដូចជាពពួកស្មៅ អង្ការដី គន្ធំថេត សណ្តែកខ្មៅ សណ្តែកគ្រប់ប្រភេទ |
| ជីភាវ | √ | ជីភាវផ្សំពីសារធាតុសរីរាង្គផ្សេងៗ ប្រើសំរាប់បង្កើនជីជាតិដី និងទំរង់ដី |
| ជីអាចម៍មាន់ | ! | អនុញ្ញាតិចំពោះមាន់ចិញ្ចឹមតាមបែបធម្មជាតិ ។ គួរត្រួតពិនិត្យប្រភព |
| ជីអាចម៍ប្រចៀវ | ! | ប្រភពល្អសំរាប់ សារធាតុផូស្វ័រ (P) ប៉ុន្តែអាល់កាឡាំងបន្តិច |

| | | |
|---|---|---|
| លាមកសត្វ | ! | • ហាមប្រើជីលាមកសត្វស្រស់ ប៉ុន្តែអាចប្រើកប់ក្នុងដី ១ខែ មុនដាំដំណាំ<br>• មិនត្រូវហាលជីលាមកសត្វនៅកណ្តាលថ្ងៃឡើយ ។ លាយជាមួយជីថ្ម ផូស្វាត អាចបង្កើនសារធាតុចិញ្ចឹមសំរាប់ដំណាំ |
| ជីខនិច | ! | អនុញ្ញាតិអោយប្រើតែក្នុងទំរង់ជាធម្មជាតិ និងប្រើជាជីបន្ទាប់បន្សំប៉ុណ្ណោះ |
| ជីកំប៉ុស្តិ៍ | √ | ប្រើប្រាស់ល្អសំរាប់ថែរក្សា និងបង្កើនគុណភាពដី តែសារធាតុផ្សំសំរាប់ធ្វើ ជីកំប៉ុស្តិ៍ ត្រូវតែជាសារៈធាតុសរីរាង្គ ដែលអាចរកបាននៅក្នុងស្រុក ។ ហាមមិនអោយប្រើ កំប៉ុស្តិ៍ចេញពីកាកសំណល់ទីក្រុង |
| កំប៉ុស្តិ៍ចេញពី កាកសំណល់ឧស្ម័ន Bio-gas | √ | មិនគួប្រើអោយលើសពី ៥តោន ក្នុង១ហិចតាឡើយ |
| ចំបើង | √ | ប្រើសំរាប់គ្របរងដំណាំ ផ្សំធ្វើជីកំប៉ុស្តិ៍ ឬកាប់លាយក្នុងដីចំការ |
| ដំណាំបង្វិល ឬឆ្លាស់ | √ | ការដាំដំណាំបង្វិល គួប្រើប្រភេទដំណាំផ្សេងៗគ្នា ដើម្បីថែរក្សាជីជាតិដី ដូចជា (១) ដាំពពួកសណ្តែក (២) ដាំពពួកដំណាំមើម (៣) ដាំពពួកដំណាំយកស្លឹក (៤) ដាំពពួកយកផ្លែ (៥) ដាំពពួកដំណាំធញ្ញជាតិ |
| បាក់តេរី រីសូប្យូម (Rhizobium) | √ | លាយជាមួយគ្រាប់ពពួកសណ្តែកមុនពេលយកទៅដាំ |
| មនាងសិលា | √ | ប្រើក្នុងទំរង់ជាធម្មជាតិ ដើម្បីបង្កើនបរិមាណកាល់ស្យូមក្នុងដី |
| សារធាតុរុក្ខជាតិផ្សេងៗ | √ | ប្រើសំរាប់កែលំអដី |
| កាកសំណល់ត្រី | ! | ប្រើនៅក្នុងជីកំប៉ុស្តិ៍ |
| ចកអាសូឡា (Azolla) | √ | មានសារធាតុអាសូតខ្ពស់ និងងាយរំដោះបានដោយសារឫសដំណាំ |

<u>ផ្នែកទី២. សំភារៈប្រើសំរាប់ការពារដំណាំ គិតទាំងសត្វល្អិត ជំងឺ និងស្មៅចង្រៃ :</u>

| សំភារៈ | សំគាល់ | បរិយាយ/លក្ខ័ណ្ឌ |
|---|---|---|
| អន្ទាក់សត្វល្អិត ស្អិត | √ | អាចប្រើសំភារៈពណ៌លឿង ដើម្បីងាយទាក់ទាញសត្វ |
| ម្សៅស្ពាន់ធ័រ | ! | ប្រើសំរាប់ការពារ ឬកំចាត់ពពួកជំងឺផ្សិត បន្តែវាមានជាអាស៊ីត ដែលអាចបណ្តាលអោយខ្លោចស្លឹក ប្រសិនបើប្រើវានៅពេលមេឃក្តៅ |
| ផេះចេញពីឧស | √ | អាចប្រើលាយជាមួយគ្រាប់ពូជមុនពេលសាប ឬការទុកដាក់គ្រាប់ពូជ |
| អាចម៍រណា | √ | ប្រើល្អដើម្បីកាត់បន្ថយការឆ្លងរាលដាលនៃជំងឺ តាមដីនិងជួយបង្កើនជីជាតិ |
| សំបកលៀស ខ្យង ឬ បង្គា ក្តាម | √ | អនុញ្ញាតិក្នុងទំរង់ធម្មជាតិ ក្នុងការបង្កើនជីជាតិដី |
| សត្វមានប្រយោជន៏ | √ | ថែរក្សាវិធានការជីវសាស្ត្រ តាមបែបធម្មជាតិ |
| ទឹកខ្មេះ | √ | លាយជាមួយទឹក ប្រើសំរាប់ការពារ និងកំចាត់ជំងឺ និងសត្វល្អិតមួយចំនួន |
| ថ្នាំ Bt (*Bacillus thuringensis)* | √ | លើកលែងតែ GMO |
| ប្លាស្ទិច | ! | ប្រើតែនៅពេលចាំបាច់ សំរាប់រុំផ្លែដំណាំ ឬគ្របរងការពារស្មៅ |

| | | |
|---|---|---|
| ដំណាំគំរប | √ | ប្រើល្អសំរាប់ការពារស្មៅ បន្ថយភាពរំហួតរបស់ទឹកក្នុងដី និរក្សាសំណើមដី |
| ដំណាំឆ្លាស់ ឬបង្វិល | √ | ជួយក្នុងការការពារការឆ្លងរាលដាលនៃសត្វល្អិត ជំងឺ និងស្មៅ |
| ដំណាំដេញសត្វ | √ | ដូចជាស្លឹកគ្រៃ និងជីគ្រប់ប្រភេទ |
| ថ្នាំជក់ | ! | ទឹកថ្នាំជក់ដែលបានពីការត្រាំជាមួយទឹក ប្រើសំរាប់ការពារសត្វល្អិត ឬជ្រលក់គ្រាប់ពូជមុនពេលដាំឬសាប ។ ហាមប្រើថ្នាំជក់ស្រស់ ។ |
| វល្លិគ្រៀស | ! | មានជាតពុលខ្សោយជាងថ្នាំជក់ ប៉ុន្តែអាចធ្វើអោយរមាស់ស្បែក ។ អាចកំចាត់ពពួកស្លាបរឹង ដង្កូវ និងរុយ |
| គំរបដី | √ | ប្រើសំភារៈពីធម្មជាតិ ដូចជាចំបើង ត្រកៀត ដើម្បីការពារស្មៅ |
| NPV | √ | ប្រើសំរាប់ការពារពពួកដង្កូវ តែហាមប្រើពពួក GMO |
| សាប៊ូដុំ | √ | ប្រើសំរាប់កំចាត់ពពួកជញ្ជាក់ ដូចជាពពួកចៃ តែអាចធ្វើអោយខ្លោចស្លឹក |
| ភ្នាក់ងារទាក់សត្វល្អិត ដូចជាផេរ៉ូមូន | √ | ប្រើសំរាប់កាត់បន្ថយបរិមាណសត្វល្អិតចង្រៃ |
| ស្មៅ | ! | ប្រើសំរាប់កំចាត់សត្វល្អិត |

**ឧបសម្ព័ន្ធទី ២. គោលការណ៍សំរាប់វាយតំលៃសំភារៈ ប្រើបន្ថែម នៅក្នុងផលិតកម្មដំណាំសរីរាង្គ**

សំភារៈទាំងអស់ គិតទាំងគ្រាប់ពូជ ជីសរីរាង្គ ថ្នាំផ្សំពីរុក្ខជាតិ ឬឧបករណ៍កសិកម្មផ្សេង១ទៀត ដែលយកមកប្រើប្រាស់នៅក្នុងចំការដំណាំសរីរាង្គ ត្រូវតែបានត្រួតពិនិត្យ និងវាយតំលៃយ៉ាងច្បាស់លាស់ ថាតើវាត្រូវបានកំណត់អោយប្រើនៅក្នុងគោលការណ៍នេះយ៉ាងដូចម្តេច ប្រសិនបើអ្នកផលិតចង់ប្រើប្រាស់វា ។ ដូចនេះ មុននឹងអនុញ្ញាតិអោយប្រើប្រាស់ សំភារៈទាំងនោះ ត្រូវឆ្លងកាត់ការវាយតំលៃតាមគោលការណ៍នៃការវាយតំលៃនេះជាមុនសិន ។

**វិធីសាស្ត្រក្នុងការវាយតំលៃ**

ក. <u>ពត៌មាន ឬឯកសារកត់ត្រា</u> : ផលិតករត្រូវតែកត់ត្រានូវពត៌មានទាំងអស់អោយបានជាប្រចាំ នូវប្រភព ទិកន្លែង និងពេលវេលានៃការដោះដូរ ឬទិញសំភារៈទាំងអស់នេះ ។ ប្រសិនបើពុំមានកត់ត្រា ឬស្គាល់ពីប្រភពអោយបានច្បាស់លាស់ទេ នោះសំភារៈទាំងអស់នោះ នឹងពុំអនុញ្ញាតិអោយប្រើប្រាស់ឡើយ ។

ខ. <u>ការវាយតំលៃសំភារៈប្រើប្រាស់</u> : ក្រៅពីសំភារៈដែលមានចែងក្នុងឧបសម្ព័ន្ធទី ១ សំភារៈដែលផលិតពីកាកសំណល់រុក្ខជាតិ ពិសត្វ ឬពីពពួកមីក្រូសារពាង្គកាយផ្សេង១ ឬសំភារៈបានពីការទិញពីគេផ្សេង អាចអនុញ្ញាតិអោយប្រើបាន លុះត្រាតែការប្រើសំភារៈទាំងនោះ ត្រូវនឹងលក្ខខ័ណ្ឌដូចខាងក្រោម :

ខ១. ការប្រើប្រាស់សំភារៈទាំងនោះ មានសារៈសំខាន់ក្នុងការការពារ និងលើកកំពស់គុណភាពផលិតផល

ខ២. សំភារៈ ឬគ្រឿងផ្សំរបស់វាត្រូវបានផលិតឡើងតាមទំរង់ ឬដំណើរការជាធម្មជាតិ និងមិនមែនជា GMO ឡើយ ។

ខ៣. ការប្រើប្រាស់នូវសំភារៈទាំងនោះ ត្រូវបានបញ្ជាក់ដោយសហគមន៍ថា វាមិនមានឥទ្ធិពលអាក្រក់មនុស្ស សត្វស្រុក សត្វមានប្រយោជន៍ និងពពួកមីក្រូសារពាង្គកាយនៅក្នុងដី និងក្នុងបរិស្ថាន

ខ៤. ការប្រើប្រាស់សំភារៈទាំងនេះ នឹងមិនប៉ះពាល់ដល់គុណភាពផលិតផលសរីរាង្គឡើង